# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀងរវាងនិយោជក ប្រតិភូបុគ្គលិក និងសហជីពកម្មករនិយោជិត នៃសណ្ឋាគារ ឡឺម៉េរីឌានអង្គរ

សណ្ឋាគារឡឺម៉េរីឌានអង្គរ ប្រតិភូបុគ្គលិក រួមនិងសហជីពកម្មករនិយោជិតវិស័យទេសចរណ៍ នៃសណ្ឋាគារឡឺម៉េរីឌានអង្គរ យល់ស្របគ្នា ក្នុងការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ២០៩នាក់ រយៈពេល ១ខែចាប់ពីថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២០។ ដោយសារស្ថានភាពធ្ងន់ធ្ងរនៃមេរោគកូវីដ-១៩ (Covid-19) ដែលធ្វើអោយភ្ញៀវដែលបានកក់បន្ទប់ស្នាក់នៅលុបចោលការស្នាក់នៅក្នុងសណ្ឋាគារស្ទើរតែទាំងស្រុង។ ក្នុងពេលព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតសណ្ឋាគារបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតដូចខាងក្រោម៖

១. ថ្នាក់ដឹកនាំកំពូលចំនួន ៥៥% នៃប្រាក់ឈ្នួលគោល

២. ថ្នាក់ដឹកនាំប្រធានផ្នែកចំនួន ៦៥% នៃប្រាក់ឈ្នួលគោល

៣. ថ្នាក់ដឹកនាំជំនួយការប្រធានផ្នែកចំនួន ៧៥% នៃប្រាក់ឈ្នួលគោល

៤. ប្រធានក្រុមចំនួន ៨៥% នៃប្រាក់ឈ្នួលគោល

៥. បុគ្គលិកនិយោជិតធម្មតាចំនួន ៩០% នៃប្រាក់ឈ្នួលគោល

ក្នុងពេលព្យួរកិច្ចសន្យាការងារនេះ សណ្ឋាគារ និងធ្វើការកែលំអរ សម្អាតបរិស្ថានសណ្ឋាគារអោយមានសណ្តាប់ធ្នាប់ និងរក្សាសោភ័ណ្ឌភាព ដើម្បីរង់ចាំទទួលភ្ញៀវវិញក្នុងពេលខាងមុខ ដូច្នេះសណ្ឋាគារតម្រូវអោយនិយោជិតកម្មករចូលរួមជាកម្លាំង ទៅតាមតារាងការងារ (Roster) ប្រចាំខែ ដែលចេញដោយប្រធានផ្នែកនីមួយៗ ហើយនិយោជិតកម្មករត្រូវផ្តិតមេដៃវត្តមានជាធម្មតា។

ដោយសារសណ្ឋាគារពុំមានចំណូលក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ រាល់អត្ថប្រយោជន៍របស់កម្មករនិយោជិតដែលបានចែងក្នុង សៀវភៅនិយោជិតកម្មករ ក៏ដូចជាក្នុងអនុសញ្ញារួមត្រូវព្យួរ រហូតដល់សណ្ឋាគារដំណើរការធម្មតាវិញ។

ថ្ងៃពុធ ១៤រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

សៀមរាបថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០

| តំណាងប្រតិភូបុគ្គលិក | តំណាងសហជីព | តំណាងសណ្ឋាគារ |
|---|---|---|
| ឆប កេទ | លី លីនដា | លី ប៊ុនហួរ |
| ប្រតិភូបុគ្គលិក | ប្រធានសហជីព | នាយកធនធានមនុស្ស |